សុន្ទរកថាស្វាគមន៍ ឯកឧត្តម បណ្ឌិត សុក ស៊ីផាន់ណា ប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថាន វបសអ-

CDRI ក្នុងពិធីបើក **សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៦** លើប្រធានបទ

**"ជំរុញការងារទៅមុខ៖ ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេស និងក្នុងតំបន់ និង**
**ឡូជីស្ទីកសម្រាប់ការតភ្ជាប់ កំណើន និងអភិវឌ្ឍន៍"**
ថ្ងៃទី៧ ខែមីនា ឆ្នាំ២០១៦
សណ្ឋាគារ សូហ្វីតែល ភ្នំពេញ ភោគីត្រា

- **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា**
  **ជាទីគោរពដ៏ខ្ពង់ខ្ពស់**
- **ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ អស់លោក លោកស្រី ជាទីគោរពរាប់អាន!**

ក្នុងនាមជាប្រធានក្រុមប្រឹក្សាភិបាល នៃវិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា ខ្ញុំមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង សូមសម្តែងនូវការស្វាគមន៍យ៉ាងកក់ក្តៅបំផុតជូនដល់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ឯកឧត្តម អ្នកឧកញ៉ា លោកជំទាវ អស់លោក លោកស្រី ចំពោះការអញ្ជើញមកចូលរួមក្នុង សន្និសីទ ចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ ២០១៦ នេះ ដែលសហការរៀបចំឡើងដោយ វិទ្យាស្ថាន បណ្តុះបណ្តាល និង ស្រាវជ្រាវ ដើម្បីអភិវឌ្ឍន៍កម្ពុជា និង ធនាគារ ANZ Royal ។

នាឱកាសដ៏វិសេសវិសាលនេះ យើងខ្ញុំសូមសម្តែងនូវកត្តញ្ញូតាធម៌ដ៏ ជ្រាលជ្រៅបំផុតជូន ចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ដែលបានផ្តល់ការជួយ គាំទ្រជារៀងរហូតមកដល់ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាប្រចាំឆ្នាំ ជាពិសេស សម្រាប់ខួបលើកទី១០នៃសន្និសីទនេះ ព្រមទាំងផ្តល់តម្លៃដល់ការងារស្រាវជ្រាវឯករាជ្យផ្នែកគោលនយោបាយអភិវឌ្ឍន៍របស់វិទ្យាស្ថានយើងខ្ញុំ។

យើងខ្ញុំក៏សូមអរគុណជាពន្លឹកផងដែរ ដល់ ធនាគារ ANZ Royal ចំពោះ កិច្ចសហការ ជាដៃគូដ៏ល្អប្រសើរ និងការតាំងចិត្តខ្ពស់ក្នុងការចូលរួមរៀបចំ សន្និសីទចក្ខុវិស័

យជាបន្តបន្ទាប់ ជាពិសេសយើងខ្ញុំសូមអរគុណដល់ លោក Grant Knuckey នាយកប្រតិបត្តិធនាគារ ANZ Royal ដែលបានជួយគាំទ្រ និងចូលរួមការងារយ៉ាងសកម្ម។ សម្រាប់សន្និសីទឆ្នាំ២០១៦ នេះ យើងខ្ញុំក៏ទទួលបានជំនួយគាំទ្រផងដែរពី ក្រុមហ៊ុនធានារ៉ាប់រង Manulife ។

សន្និសីទចក្ខុវិស័យប្រទេសកម្ពុជាលើកទី១០ នេះ វិទ្យាស្ថាន CDRI និង ធនាគារ ANZ Royal បានរួមសហការគ្នារៀបចំឡើងលើប្រធានបទ "ជំរុញការងារទៅមុខ៖ ហេដ្ឋារចនាសម្ព័ន្ធនៅក្នុងប្រទេស និងក្នុងតំបន់ និង ឡូជីស្ទីកសម្រាប់ការតភ្ជាប់ កំណើន និងអភិវឌ្ឍន៍" ។ ជាថ្មីម្តងទៀត សន្និសីទប្រចាំឆ្នាំនេះ បានអញ្ជើញថ្នាក់ដឹកនាំពីគ្រប់វិស័យ មកជួបជុំគ្នាដើម្បីពិនិត្យពីសមិទ្ធផល ដែលកម្ពុជា សម្រេចបាន ធ្វើការផ្លាស់ប្តូរមតិ យោបល់គ្នា និងពិភាក្សាពីយុទ្ធសាស្រ្តសម្រាប់ ការអភិវឌ្ឍ និងការរីកចម្រើននៃ ប្រទេសកម្ពុជាទៅអនាគត ព្រមទាំងចងក្រងជាអនុសាសន៍ផ្នែក គោលនយោបាយ សម្រាប់ការធ្វើសកម្មភាព។

សន្និសីទចក្ខុវិស័យលើកនេះ ប្រារព្ធឡើងចំពេលដ៏សំខាន់មួយ បន្ទាប់ពីប្រទេសកម្ពុជាចូលរួមសម្រេចបាននូវ សហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥ ប៉ុន្តែត្រូវធ្វើការងារជាច្រើនទៀត ដើម្បីចាប់យកឱកាសល្អ និងទាញយកអត្ថប្រយោជន៍ឲ្យបានច្រើនជា អតិបរមាពីសហគមន៍នេះ។ ជាថ្មីម្តងទៀត សន្និសីទនឹងផ្តោតលើបញ្ហាសំខាន់ៗដែល ជាកត្តាកំណត់សម្រាប់ឲ្យប្រទេសកម្ពុជា សម្រេចបានអនាគតដ៏រុងរឿង។បញ្ហាទាំងនេះ រួមមាន

(១)តើត្រូវធ្វើអ្វីខ្លះដើម្បីដោះស្រាយបញ្ហាដែលយើងកំពុងប្រឈម ក្នុងការពង្រីក និងពង្រឹងឡូជីស្ទីក និងហេដ្ឋារចនាសម្ព័ន្ធក្នុងប្រទេស និងក្នុងតំបន់ ដើម្បីបង្កើន ការតភ្ជាប់ កំណើន និងការអភិវឌ្ឍឧស្សាហកម្ម,

(២)តើមានតួអង្គសំខាន់ៗណាខ្លះ និងតើមានបញ្ហាចោទចម្បងៗអ្វីខ្លះ ដែលយើងត្រូវយកចិត្តទុកដាក់ក្នុងការធ្វើផែនការ ការអនុវត្តការងារ និងការកសាង ក្របខ័ណ្ឌច្បាប់ និងបទបញ្ញត្តិ និង

(៣)តើមានកត្តាសំខាន់ៗអ្វីខ្លះដែលកំណត់ជោគជ័យរបស់យើង ក្នុងការធ្វើការងាររួមគ្នា ដើម្បីសម្រេចបានតាមគោលដៅអភិវឌ្ឍន៍ជាតិទាំងនេះ?

នាព្រឹកនេះយើងខ្ញុំមានភ័ព្វសំណាងជាអនេកនិងមានកិត្តិយសដ៏ខ្ពង់ខ្ពស់ដោយ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** អញ្ជើញចូលរួមផ្តល់មតិណែនាំ និងចក្ខុវិស័យ អំពីបញ្ហាដូចបានលើកឡើងនៅខាងលើ។

នៅក្នុងកិច្ចពិភាក្សាផ្លាស់ប្តូរយោបល់គ្នាយ៉ាងសកម្មក្នុងថ្ងៃនេះ យើងខ្ញុំសង្ឃឹមថានឹងអាចចូលរួមចំណែកក្នុងការរែកញែក និងលើកជាអនុសាសន៍ផ្នែកគោលនយោបាយទាក់ទងនឹងសំណួរសំខាន់ៗ
ដូចតទៅ៖

- តើហេដ្ឋារចនាសម្ព័ន្ធ ការដឹកជញ្ជូន និងប្រព័ន្ធឡូជីស្ទីកបែបណា ដែលសមស្របបំផុតសម្រាប់ជួយឲ្យប្រទេសកម្ពុជាសម្រេចបានតាម គោលដៅអភិវឌ្ឍន៍របស់ខ្លួន?

- តើយន្តការអ្វីខ្លះមានប្រសិទ្ធភាពបំផុត សម្រាប់លើកកម្ពស់ការសម្របសម្រួល និង សហប្រតិបត្តិការ ដើម្បីសម្រេចបានលទ្ធផលប្រកបដោយជោគជ័យ?

- តើការបង្កើតក្រុមការងារឡូជីស្ទីក និងដឹកជញ្ជូនថ្នាក់ជាតិ ជាយន្តការមានប្រយោជន៍ និងងាយអនុវត្តប៉ុណ្ណាដែរដើម្បីជួយបង្កើនភាពរលូនគ្នាផ្នែកគោលនយោបាយនិងកិច្ចសហការឈានទៅសម្រេចគោលដៅអភិវឌ្ឍន៍ជាតិ?

- តើយើងធ្វើយ៉ាងណាអាចប្រើប្រាស់បានប្រសើរបំផុតនូវ ធនាគារវិនិយោគហេដ្ឋារចនាសម្ព័ន្ធអាស៊ី (AIIB), the Silk Road Fund និង ភាពជាដៃគូមានស្រាប់ជាមួយអង្គការពហុភាគីដទៃទៀតនោះ?

នាឱកាសនេះ យើងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុតដោយ **សម្តេចអគ្គមហា សេនាបតី តេជោ ហ៊ុន សែន** បានអញ្ជើញចូលរួមជាអធិបតី ផ្តល់នូវមតិណែ នាំបំផុសគំនិត និង ផ្តល់ជាបរិការណ៍សម្រាប់កិច្ចពិភាក្សា របស់អង្គសន្និសីទ។

តាងនាម ឲ្យវិទ្យាស្ថានបណ្តុះ បណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា និង ធនាគារ ANZ Royal ខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់បំផុត សូមគោរពអញ្ជើញ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងសុន្ទរកថាគន្លឹះបើកសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៦ និងផ្តល់មតិណែ នាំ ដល់អង្គសន្និសីទ។

សូមអរគុណ!